លេខ:០១ ខែកុម្ភៈ ឆ្នាំ២០០៧ ព្រឹត្តិបត្រ ស្ម័គ្រចិត្តដើម្បីសហគមន៍

# ស្វែងយល់ពីកម្មវិធីស្ម័គ្រចិត្តដើម្បីសង្គម (ស.ដ.ស)

## មតិចាប់អារម្មណ៍របស់អ្នកសំរបសំរួលកម្មវិធី ស.ដ.ស

ស.ដ.ស ជាថ្នាលបណ្តុះ និងកត្តាលីករសំរាប់ជំរុញលើកកំពស់សមត្ថភាព ចំណេះដឹងរួមផ្សំនឹងចំណេះអនុវត្តដល់យុវជនឱ្យចូលរួមដោយផ្ទាល់ក្នុងសហគមន៍មូលដ្ឋាន។ ភាពរីកចំរើន និងការខិតខំប្រឹងប្រែងរបស់អ្នកពាក់ព័ន្ធកម្មវិធី ស.ដ.ស បានប្រសូត្រចេញនូវ *កម្មវិធីស្ម័គ្រចិត្តដើម្បីសង្គម* ដែលសមស្របទៅនឹងទិសដៅយូរអង្វែងជាមួយគោលនយោបាយរាជរដ្ឋាភិបាលក្នុងការលើកកំពស់ការចូលរួមដោយស្ម័គ្រចិត្តរបស់យុវជនក្នុងប្រទេសកម្ពុជា និងនិន្នាការពិភពលោក។ កម្មវិធី ស.ដ.ស បានស្ថាបនាសកម្មភាពសាកល្បងក្នុងឆ្នាំ ២០០៤ និងបន្តរហូតដល់បច្ចុប្បន្នដែលមានចំនួនកើនឡើងជាលំដាប់ពីមួយជំនាន់ទៅមួយជំនាន់ ដើម្បីបំពេញសេចក្តីត្រូវការរបស់យុវជន និងសង្គមកម្ពុជា។

ជាតឹកតាងនៃកិច្ចខិតខំប្រឹងប្រែង និងការរៀនសូត្រ កម្មវិធី ស.ដ.ស បានរៀបរៀងនូវព្រឹត្តិបត្រ *ស្ម័គ្រចិត្តដើម្បីសហគមន៍* ជាស្នាដៃលើកទី១របស់កម្មវិធី ស.ដ.ស ដើម្បីបង្ហាញ និងឆ្លុះបញ្ចាំងនូវសកម្មភាពការងារអ្នកស្ម័គ្រចិត្ត អង្គការដៃគូ និងរឿងរ៉ាវសហគមន៍ក្នុងន័យស្ថាបនា និងការលើកទឹកចិត្តយុវជនឱ្យចូលរួមរៀនសូត្រ ព្រមទាំងចែករំលែកនូវសក្តានុពលភាព និងប្រាជ្ញារបស់ពួកគេសំរាប់សហគមន៍មូលដ្ឋាន និងសង្គមកម្ពុជា។

នេះគឺជាចំណាប់អារម្មណ៍ និងការចែករំលែកពុទ្ធិរបស់ខ្ញុំ សំរាប់លើកស្ទួយ និងជំរុញសកម្មភាពអោយប្រព្រឹត្តិទៅបន្ត ហើយនិងទទួលយករាល់មតិសរសើរិះគន់ស្ថាបនា ដើម្បីកែលំអព្រឹត្តិបត្រក៏ដូចជាកម្មវិធី ស.ដ.ស ឆ្ពោះទៅរកការអភិវឌ្ឍន៍ និងការរីកចំរើនប្រកបដោយសេចក្តីថ្លៃថ្នូរ។

ជាចុងក្រោយតាងនាមកម្មវិធី ស.ដ.ស និងខ្ញុំផ្ទាល់ សូមថ្លែងអំណរគុណ និងស្វាគមន៍រាល់មតិកែលំអ។

**ហាច គីមគង់**



សកម្មភាព ស.ដ.ស និង អ្នកស្ម័គ្រចិត្ត ជាមួយដៃគូការងារនៅមូលដ្ឋាន

**មាតិកា**


- មតិចាប់អារម្មណ៍របស់អ្នកសំរបសំរួលកម្មវិធី ស.ដ.ស...............០១
- ប្រវត្តិកម្មវិធីស្ម័គ្រចិត្តដើម្បីសង្គម (ស.ដ.ស).......................០២
- អត្ថន័យនៃការស្ម័គ្រចិត្តរបស់ ស.ដ.ស..............................០២
- អ្នកស្ម័គ្រចិត្តជំនាន់ទី១របស់កម្មវិធី ស.ដ.ស ឆ្នាំ២០០៥-២០០៦.....០២
- អ្នកស្ម័គ្រចិត្តជំនាន់ទី២របស់កម្មវិធី ស.ដ.ស ឆ្នាំ២០០៦-២០០៧....០៣
- ដៃគូរបស់កម្មវិធី ស.ដ.ស........................................០៤

## ប្រវត្តិកម្មវិធីស្ម័គ្រចិត្តដើម្បីសង្គម

*កម្មវិធី ស.ដ.ស* ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៤ តាមរយៈការពិភាក្សា និងការសិក្សារួមគ្នាជាមួយបណ្តាអង្គការដែលមានបទពិសោធន៍មួយចំនួនដូចជា: សេវាកម្មអ្នកស្ម័គ្រចិត្តថៃ (TVS) មូលនិធិអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រក្នុងទីក្រុង (UPDF) សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) និងដេប៉ាតេម៉ង់បរិស្ថាន នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ កម្មវិធី ស.ដ.ស មានបំណងពង្រឹង និងចូលរួមចំណែកក្នុងការកសាងសង្គមនៅទីកន្លែងនានា ក្នុងប្រទេសកម្ពុជា ជាពិសេសប្រជាជននៅតាមមូលដ្ឋាន តាមរយៈការផ្សារភ្ជាប់អ្នកស្ម័គ្រចិត្តជាយុវជនទៅនឹងការងារសង្គម។

## អត្ថន័យនៃការស្ម័គ្រចិត្តរបស់ ស.ដ.ស

នាពេលបច្ចុប្បន្ននៅប្រទេសកម្ពុជា *អ្នកស្ម័គ្រចិត្ត*មិនទាន់ត្រូវបានគេទទួលស្គាល់ និងឱ្យតំលៃអោយបានទូលំទូលាយនោះទេ ដោយសារមានការយល់ឃើញខុសៗគ្នាអំពីអត្ថន័យរបស់វា។ ជួនកាលអ្នកស្ម័គ្រចិត្តត្រូវបានចាត់ទុកថាជាអ្នកស្វែងរកបទពិសោធន៍ ហើយនៅពេលខ្លះបានទទួលរងនូវការកេងប្រវ័ញ្ចកំលាំងពលកម្មទៀតផង។

បើតាមលោក Peter Dobkin Hall (Developing and Managing Volunteer Programs) មានប្រសាសន៍ថា *ការស្ម័គ្រចិត្តគឺការធ្វើដោយគ្មានប្រាក់រង្វាន់ និងធ្វើដើម្បីផ្តល់អត្ថប្រយោជន៍ទៅសហគមន៍។* ជាការពិតការស្ម័គ្រចិត្តជាការងារដែលប្រកបដោយសេចក្តីថ្លៃថ្នូរ មានការលះបង់ ជាពិសេសបានរួមចំណែកចំពោះសង្គមកម្ពុជា និងខ្លួនឯងឱ្យមានការរីកចំរើន។ លើសពីនេះទៅទៀតអ្នកស្ម័គ្រចិត្តគួរត្រូវបានគាំទ្រទាំងផ្នែកសម្ភារៈ ថវិការ និងស្មារតី។

ការស្ម័គ្រចិត្តជាការចូលរួមអភិវឌ្ឍន៍សង្គម

## អ្នកស្ម័គ្រចិត្តជំនាន់ទី១ ឆ្នាំ ២០០៥-២០០៦
## "ពន្លឺអ្នកស្ម័គ្រចិត្តដើម្បីអភិវឌ្ឍន៍"



ក. **ផា សិលា**

សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA) ខេត្តស្ទឹងត្រែង

**គំរោង:** គ្រប់គ្រងធនធានទឹក



លោក **ប៉ែន សុមុនី**

គណៈកម្មាធិការបម្រើក្វេគ័រអាមេរិកាំង (AFSC) ខេត្តកោះកុង

**គំរោង:** អភិវឌ្ឍន៍សហគមន៍ និងស្រាវជ្រាវអំពីបញ្ហាសហគមន៍នេសាទតាមតំបន់ឆ្នេរសមុទ្រ



ក. **ពេជ្រ ម៉ានី**

មូលនិធិអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រក្នុងទីក្រុង (UPDF) ក្រុងភ្នំពេញ

**គំរោង** : សន្សំប្រាក់



លោក **សួន សៅបុត្រា**

**អង្គការ:**សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) ខេត្តសៀមរាប

**គំរោង** : ឃ្លាំមើលទន្លេសាប



លោក **វ៉េត សុនីម**

**អង្គការ:** មួប់បៃតង (MB) ខេត្តកំពង់ស្ពឺ

**គំរោង:**សាលារៀននិងបរិស្ថាន និងគំរោងសហគមន៍ព្រៃឈើ







**អ្នកស្ម័គ្រចិត្តជំនាន់ទី២របស់កម្មវិធី ស.ជ.ស ឆ្នាំ ២០០៦-២០០៧**

**"ស្ម័គ្រចិត្តដើម្បីការអភិវឌ្ឍន៍ជាវិជ្ជមាន"**

តាមលទ្ធផលនៃគំរោងអនុវត្តសាកល្បងបានបង្ហាញនូវផ្លែផ្កាល្អប្រសើរ និងដោយសារមើលឃើញពីតំរូវការចាំបាច់ ព្រមទាំងមានការសហការពីដៃគូ និងប្អូនៗជាយុវជនក្នុងការចូលរួមចំណែកកសាងសមត្ថភាពផ្ទាល់ខ្លួន និងអភិវឌ្ឍន៍សង្គមមូលដ្ឋានជនបទ ដូចនេះ កម្មវិធី ស.ជ.ស បានបង្កើនចំនួនអ្នកស្ម័គ្រចិត្តពី ៥រូបក្នុងឆ្នាំ ២០០៥-២០០៦ ទៅ ១០រូប ក្នុងឆ្នាំ ២០០៦-២០០៧។

ខាងក្រោមនេះជាទីតាំងរបស់អ្នកស្ម័គ្រចិត្តជំនាន់ទី២ជាមួយដៃគូរបស់កម្មវិធី ស.ជ.ស ឆ្នាំ ២០០៦-២០០៧

ស្ម័គ្រចិត្តការលះបង់ដើម្បីសង្គមយើងទាំងអស់គ្នា

## អ្នកស្ម័គ្រចិត្តជំនាន់ទី ២

លោក **លី នងមេត្រា**
**អង្គការ :** ទ្រទ្រង់ស្ត្រីខ្មែរ
**គំរោង :** អភិវឌ្ឍន៍សហគមន៍ចំរុះ

លោក **តាប់ តាំងហ៊ួ**
**អង្គការ:** ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ខេត្តកំពង់ធំ
**គំរោង:** អភិវឌ្ឍន៍សហគមន៍ចំរុះ

លោក **ស្លុង សុផាត**
**អង្គការ:** សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល
**គំរោង:** សម្ព័ន្ធប្រជានេសាទកម្ពុជា

ក. **យន សុភា**
**អង្គការ:** អុកស្វាមអូស្ត្រាលី
**គំរោង:** អភិវឌ្ឍន៍សហគមន៍ចំរុះ




លោក **យិបយ៉ុម ឆាយា**
**អង្គការ:** សកម្មភាពអភិវឌ្ឍកសិកម្ម
**គំរោង:** ចិញ្ចឹមទានិងក្រុមជួយខ្លួនឯង

ក. **ជ័យ សុធីរា**
សមាគមថែរក្សាបរិស្ថាននិងវប្បធម៌
**គំរោង:** គ្រប់គ្រងធនធានទឹក

លោក **ពាក់ តូក្បា**
គណៈកម្មាធិការបម្រើក្វេគ័រអាមេរិកាំង

ក. **បុណ្យ រចនា**
មូលនិធិអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រក្នុងទីក្រុង

លោក **ព្រឿង សំអុន**
**អង្គការ:** ម្លប់បៃតង
**គំរោង:** ទេសចរណ៍ធម្មជាតិគ្រប់គ្រងដោយសហគមន៍

ក. **សេក ផារី**
សមាគមធាងត្នោត
**គំរោង:** សង្កេតការណ៍ដីធ្លី

## ដៃគូរបស់កម្មវិធី ស.ជ.ស

ដៃគូរបស់ ស.ជ.ស ជាទីកន្លែងដែលជួយណែនាំដល់យុវជនទើបបញ្ចប់ការសិក្សាពីសាលា (អ្នកដែលមានតែចំណេះដឹង) ក្នុងការចាប់ផ្តើមរៀនសូត្រ និងចែករំលែកចំណេះដឹងដល់សហគមន៍តាមរយៈការអនុវត្តផ្ទាល់ជាមួយថ្នាក់មូលដ្ឋាន ដើម្បីអោយពួកគេទទួលបានចំណេះធ្វើ។ បើគ្មានដៃគូការងារ និងសហគមន៍នេះទេ យុវជននឹងពុំមានភាពប្រាកដប្រជា និងទិសដៅច្បាស់លាស់ទេ។ កម្មវិធី ស.ជ.ស មានបណ្តាញដៃគូការងារច្រើនរួមមានអង្គការដៃគូក្រៅ និងក្នុងស្រុក សហគមន៍ ស្ថាប័ន និងអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធ។

ដៃគូទាំងនោះកំពុងធ្វើលើផ្នែកអប់រំបរិស្ថាន វប្បធម៌ គ្រប់គ្រងធនធានធម្មជាតិ ស្ត្រីនឹងការអភិវឌ្ឍន៍ ការអភិវឌ្ឍន៍សហគមន៍ សហគមន៍ជនក្រីក្រក្នុងទីក្រុងជាដើម។

### ដៃគូការងាររបស់កម្មវិធី ស.ជ.ស ដែលអ្នកស្ម័គ្រចិត្តបាននឹងកំពុងធ្វើការជាមួយ

- សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA) ខេត្តស្ទឹងត្រែង
- អង្គការម្លប់បៃតង (Mlup Baitong) ខេត្តកំពង់ស្ពឺ
- គណៈកម្មាធិការបម្រើក្វេគ័រអាមេរិកាំង (AFSC) ខេត្តកោះកុង
- អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ខេត្តកំពង់ធំ (BFDK) ខេត្តកំពង់ធំ
- អង្គការទ្រទ្រង់ស្ត្រីខ្មែរ (COWS) ខេត្តកំពង់ធំ
- មូលនិធិអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រក្នុងទីក្រុង (UPDF) ក្រុងភ្នំពេញ
- អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) ខេត្តបាត់ដំបង
- អង្គការអុកស្វាមអូស្ត្រាលី (Oxfam Australia) ខេត្តស្ទឹងត្រែង
- សមាគមធាងត្នោត (STT) ខេត្តកំពត
- អង្គការសកម្មភាពអភិវឌ្ឍន៍កសិកម្ម (ADA) ខេត្តបាត់ដំបង

**អ្នកស្ម័គ្រចិត្ត**

អាស័យដ្ឋានទំនាក់ទំនង៖
ការិយាល័យ៖ #៨០B ផ្លូវ ៣៨៤
សង្កាត់ទួលស្វាយព្រៃII ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ទូរសារ៖ (៨៥៥)៩២ ៥៧៦ ៦០៧/៩២ ៦៧៨ ១៩៧
*E-mail:kimkongham@yahoo.com*

**គណៈកម្មការត្រួតពិនិត្យ**
សាស្ត្រាចារ្យ ហម គឹមគង់
លោក សុខ វិសាល លោក អោម សុផាណា
លោក សូត្រ សុផុន លោក មាស គឹមសេង

**រៀបរៀងដោយ៖**
កម្មវិធី ស.ជ.ស

ឧបត្ថម្ភដោយ៖ ICCO